ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៦ សរ

ក្រសួងមុខងារសាធារណៈ រដ្ឋបាល
ប៉ុល លេខ: ៤១៣៣ មកដល់ថ្ងៃទី ៣១ ខែ ០៧ ឆ្នាំ ១៥ ម៉ោង ១៥:៣០

ន. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់
ប៉ុល លេខ: ៦៧៤ ថ្ងៃទី ២៤ ខែ ០៨ ឆ្នាំ ១៥ ម៉ោង:

# សារាចរ

## ស្តីពី

## វិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ ជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ

អនុលោមតាមច្បាប់ភូមិបាល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨, ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ, អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន តម្រូវឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ លើកសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញនីតិវិធីបន្ត ស្នើសុំរាជរដ្ឋាភិបាលលើសំណើធ្វើប្រទានកម្ម ដីធ្លី និងលំនៅដ្ឋាន ជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដែលបាន និងកំពុងស្នាក់នៅ និងអាស្រ័យផលអស់រយៈពេលយូរមកហើយ លើទ្រព្យសម្បត្តិរដ្ឋទាំងនោះ។

ដោយយកចិត្តទុកដាក់ជាប្រចាំដល់ជីវភាពរបស់ប្រជាពលរដ្ឋ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដែលមានការលំបាកពុំមានលំនៅឋានច្បាស់លាស់សម្រាប់រស់នៅ និងសម្រាប់បម្រើដល់ជីវភាព និងដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងមានលក្ខណៈសមធម៌ក្នុងសង្គម រាជរដ្ឋាភិបាលសម្រេចដាក់ចេញជាវិធាន និងកំណត់ជាលក្ខណៈវិនិច្ឆ័យធ្វើប្រទានកម្មដីធ្លី និងលំនៅឋានជូន ប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដែលបាន និងកំពុងស្នាក់នៅ និងអាស្រ័យផលអស់រយៈពេលយូរមកហើយលើទ្រព្យសម្បត្តិរដ្ឋ ដូចខាងក្រោម÷

១. ប្រជាពលរដ្ឋ ឬ មន្ត្រីរាជការ ដែលអនុញ្ញាតឱ្យបានកាន់កាប់ និងអាស្រ័យផលលើដីរដ្ឋ ទទួលបាននូវកម្មសិទ្ធិស្របច្បាប់ លុះត្រាតែ÷

- មានប្រវត្តិ និងអត្តសញ្ញាណតាំងទីលំនៅ និង/ឬ អាស្រ័យផលលើដីនោះ យ៉ាងតិចដប់ (១០)ឆ្នាំ និងត្រូវកំណត់ឆ្នាំចុងក្រោយបញ្ឈប់ការដោះស្រាយការកាន់កាប់លើទ្រព្យសម្បត្តិរដ្ឋទៀតដោយគិតត្រឹមឆ្នាំ២០១៥ និងដោយមានការបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច។

- ជាប្រជាពលរដ្ឋ ឬ មន្ត្រីរាជការក្រីក្រ មានជីវភាពខ្វះខាតពិតប្រាកដ និងមិនមានដី ឬ ផ្ទះជាកម្មសិទ្ធិផ្សេងទៀត ឬ បើមានកម្មសិទ្ធិផ្សេង ត្រូវមានការពិនិត្យ និងវាយតម្លៃឱ្យបានច្បាស់លាស់ ប្រកបដោយសុចរិតភាពដែលអាចទទួលយកបាន។ ការផ្តល់ជូននេះ ត្រូវមានលក្ខណៈសមធម៌ និងសម្រាប់តម្រូវការជាមូលដ្ឋានចាំបាច់ សម្រាប់ជាលំនៅឋាន និង/ឬ សម្រាប់ធ្វើកសិកម្ម ជាលក្ខណៈគ្រួសារប៉ុណ្ណោះ ដែលជៀសវាងអំពើកេងប្រវ័ញ្ចទ្រព្យសម្បត្តិរដ្ឋ។

២. ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការចម្រុះមួយ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងពីតំណាងក្រសួង ស្ថាប័ន/អង្គភាពពាក់ព័ន្ធមានសមត្ថកិច្ច ដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពីទំហំដី និង/ឬ លំនៅឋានជាស្តង់ដាររួមមួយ សម្រាប់ធ្វើប្រទានកម្មជូនពួកគាត់ទៅតាមស្ថានភាពទីតាំងជាក់ស្តែង និងឈរលើគោលការណ៍សមធម៌ និងតម្លាភាព។

៣. រាល់ការធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ឬ មន្ត្រីរាជការ ត្រូវមានការវាយតម្លៃលើទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើប្រទានកម្ម ដោយឈរលើមូលដ្ឋាននៃតម្លៃគិតពន្ធលើអចលនវត្ថុដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ ឬ តម្លៃទីផ្សារជាក់ស្តែង ដើម្បីកំណត់ចំនួនទឹកប្រាក់ច្បាស់លាស់ ក្នុងការជម្រះចេញពីបញ្ជី សារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងទំហំជាទឹកប្រាក់នៃវិភាគទាន ដែលរដ្ឋបានផ្តល់ជូនប្រជាពលរដ្ឋ ឬ មន្ត្រីរាជការ តាមករណីជាក់ស្តែងនីមួយៗ ដើម្បីរួមចំណែកដោះស្រាយសេចក្តីត្រូវការ និងលើកស្ទួយជីវភាពរបស់ពួកគាត់។

៤. ការកាន់កាប់រយៈពេលប្រាំ (០៥)ឆ្នាំ បន្ទាប់ពីរដ្ឋបានផ្តល់ជូន ទើបអាចស្នើសុំវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបាន ដោយអនុលោមតាមគោលការណ៍ផ្តល់សម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋ។

៥. ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលធ្វើការសម្រេចតាមស្ថានភាពជាក់ស្តែង។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត អង្គភាពសាធារណៈប្រហាក់ប្រហែលរដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៧ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- រដ្ឋបាលរាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ